 ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

៙៙៙

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១០៦

ចុះថ្ងៃទី ២៧.០៤.៩៨

<u>សាលដីកា</u>

លេខ: ៣៥

ចុះថ្ងៃទី ០៤.០៣.៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២ - លោក ខែប៉ន ញ៉ិន ជាចៅក្រម

៣ - លោក ទៀល ឆួន ជាចៅក្រម

៤ - លោក ជីវ កេង ជាចៅក្រម

៥ - លោក សោម សិរីវឌ្ឍ ជាចៅក្រមបម្រុងការជំ

ក្រឡាបញ្ជី

លោក ទេវ៉ិ ជាណា

តំណាងអយ្យការ

លោក ដួន ស៊ិនទៀង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១០ ចុះថ្ងៃទី ១២.០៧.៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៤ ចុះថ្ងៃទី ២៦.១២.៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ មុំ ត្រាត អាយុ ៤៨ ឆ្នាំ ជាតិខ្មែរ មុខរបរ ប្រធានមន្ទីរ ទីលំនៅ ភូមិព្រែកមហាទេព ឃុំស្វាយទៀប ស្រុកស្វាយទៀប ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ មុំ ពត ម្តាយឈ្មោះ ប៉ិច កេង "ស" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ថែកន សាម៉ន អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីនៅផ្ទះលេខ ៥៨ ក្រុមទី ៣៣ ភូមិព្រែកមហាទេព សង្កាត់ឯករាជ ទីរួមខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ថែកន សាន "រ" ម្តាយឈ្មោះ សុច ឌួច "រ" ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារសំណងអន្តរាយ

បានឃើញបណ្តឹងសាទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៩៨ របស់ឈ្មោះ មុំ វិរៈវឌ្ឍ ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១០៦ ចុះថ្ងៃទី ២៧.០៤.៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១២.០៥.៩២ របស់ឈ្មោះ ថែកន សាម៉ន ប្តឹងទាមទារសំណងជួសជុលការខូចខាតផ្ទះចំនួន ២០០.០០០រៀល ពីឈ្មោះ មុំ ត្រាតដោយអាងហេតុថា ដើមដូងមួយដើមរបស់ មុំ ត្រាត បានធ្លាក់រលំសង្កត់លើផ្ទះរបស់ខ្លួនបណ្តាលអោយធ្លាក់ជញ្ជាំង , ផ្ទាន , សង្កសីមួយចំនួនទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨៤ ចុះថ្ងៃទី ១៩.០៨.៩៥ របស់តុលាការខេត្តបាត់ដំបង

ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១ - ក - ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១២.០៥.៩២ របស់ឈ្មោះ កែវ សាម៉ន ជាដើមចោទ ប្ដឹងទាមទារសំណងការអន្តរាយបណ្ដាលពីដើមដូងធ្លាក់លើផ្ទះ ពីឈ្មោះ មុំ ព្រាត ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

- ខ - ទទួលយកសំណូមពរនាពេលសវនាការរបស់ដើមចោទ សុំទាមទារសំណងការអន្តរាយ និង ជំងឺចិត្ត ទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

- គ - លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២១.០២.៩៥ របស់ឈ្មោះ មុំ ព្រាត ជាចុងចម្លើយធ្វើការផ្ទេរ អោយឈ្មោះ ណាំ ស៊ុនលាង ត្រូវជាប្រពន្ធមកជាតំណាងស្របច្បាប់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - អោយឈ្មោះ មុំ ព្រាត ជាចុងចម្លើយ ចេញសំណងការអន្តរាយ និង ជំងឺចិត្តជាប្រាក់រៀល ស្មើនឹងប្រាក់បាតចំនួន ៥០០០បាត អោយឈ្មោះ កែវ សាម៉ន ជាដើមចោទ ។ ដើមចោទទាមទារលើសពីនេះបដិសេធចោល ។ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។ តាមមាត្រា ១២៧ និង មាត្រា ១២៨ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨.១០.៨៨ ។

៣ - បង្គាប់អោយឈ្មោះ មុំ ព្រាត ជាចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដីគឺ:-

- ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹងចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣០០០រៀល,

- ចំណាយក្នុងកិច្ចស៊ើបអង្កេតចំនួន ២០០០រៀល សរុប ៧០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់ប្រដាប់ក្ដី ដែលដើមចោទបានបង់ទុករួចហើយ បើរួមឧទ្ធរណ៍ អោយចុងចម្លើយសងប្រាក់ ៧០០០រៀល ទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រចំនួន ១ភាគ ៥០០០០០ / ១០០ ស្មើ ៥០០០រៀល ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ ៨០ភាគរយ និង ២០ ភាគរយ សំរាប់រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ ក្រ ចុះថ្ងៃទី ០៨.០២.៩៥ ។

៤ - សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។ បើកផ្លូវឧទ្ធរណ៍ ២ ខែ គិតពីថ្ងៃកាត់ក្ដីតទៅ ។

បាន ឃើញសេចក្ដីសុំប្ដឹងតវ៉ាលេខ ១១១ ចុះថ្ងៃទី ១៦.១០.៩៥ របស់ឈ្មោះ មុំ ព្រាត ប្ដឹងមិនសុខ នឹងសេចក្ដីសំរេចរបស់តុលាការខេត្តបាត់ដំបងទាំងមូល ។

បាន ឃើញសាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២.០១.៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១ - ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦.១០.៩៥ របស់ឈ្មោះមុំ ព្រាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២ - តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៨៤ ចុះថ្ងៃទី ១៥.០៨.៩៥ របស់តុលាការខេត្តបាត់ដំបង

ទុកជាបានការពេញទាំងមូល ។

៣ - ទីបន្ទាល់ប្រាក់ប្រដាប់ក្តីដែលសាលាឧទ្ធរណ៍ចំនួន ១៣០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ ក្នុងនោះពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ២៥៥០រៀល ឈ្នួលក្រឡាបញ្ជីការហិបប្រាក់ចំនួន ៤៥០រៀល ឈ្នួលអ្នកប្រគល់ដីកាកោះចំនួន ៥០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការចំនួន ៥០០០រៀល ។

៤ - សាលដីកានេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសារទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសារទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៨៨ របស់ឈ្មោះ មុំ វរះរឌី ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា

ក្រោយពីបានពិនិត្យគ្រប់ឯកសារពាក់ព័ន្ធរឿងក្តីនេះមក តំណាងមហាអយ្យការយល់ឃើញថា សាលាឧទ្ធរណ៍សំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយដោះសាររបស់ឈ្មោះ មុំ វរះរឌី នៅពេលជំនុំជំរះថា ក្នុងពាក្យបណ្តឹងដើមចោទសុំសងថៃ ២០ ម៉ឺនរៀលទេ តែតុលាការអោយសង ៥០០០ បានទៅវិញ ខ្លួនឆ្ងល់ថាតើគ្រប់គ្នាពេលខ្វល់ព្រួយមានវត្តអំណាចជួយដោះស្រាយយកចិត្តទុកដាក់ ចំពោះខ្លួនទៅជាសងតែវិញ ។ ខ្លួនចង់ដឹងថាមានច្បាប់ណាដែលកំណត់អោយខ្លួនសង ។

បានស្តាប់សារណារបស់ឈ្មោះ ថែកវ សាម៉ន

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់លោក មុំ វរះរឌី និង សារណារបស់លោក ថែកវ សាម៉ន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសារទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៨៨ របស់លោក មុំ វរះរឌី តំណាងអោយលោក មុំ ត្រាត ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី១២.១០.៨៨ របស់សាលាឧទ្ធរណ៍ទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាដើមដូងមួយដើមរបស់លោក មុំ ត្រាត ពិតជាបានធ្លាក់លើផ្ទះរបស់លោក ថែកវ សាម៉ន បណ្តាលអោយមានការខូចខាតផ្ទះលោក ថែកវ សាម៉ន ប្រាកដមែន ។ ដូច្នេះលោក មុំ ត្រាត ត្រូវទទួលខុសត្រូវ ដូចដែលមានចែងក្នុងមាត្រា ១២៦ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨.១០.៨៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា ការដែលលោកមុំ វរះរឌី លើកឡើងថា ការធ្លាក់ដើមដូងរបស់លោកគឺបណ្តាលបាតុភូតធម្មជាតិនោះពុំមានភស្តុតាងបញ្ជាក់អោយបានថាជាករណីប្រធានសក្តិឡើយ ហើយការកំណត់សំណងរបស់តុលាការ គឺធ្វើឡើងតាមការអង្កេត និងតាមសំណូមពរជនរងគ្រោះ ។



៣/

- យល់ឃើញថា លោក ង៉ែត សាម៉ន បានធ្វើសារណាការពាររឿងក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២.០១.៥៨ របស់សាលាឧទ្ធរណ៍បំរើសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

សំរេចសេចក្តីចំពោះមុខលោក មុំ វរេះរើង កំបាំងលោក ង៉ែត សាម៉ន

ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ៥០ ចុះថ្ងៃទី ០៣.០៣.៥៨ របស់លោក មុំ វរេះរើង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ១២.០២.៥៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣ - ទីបញ្ញើប្រាក់ប្រដាប់ក្តីដែលលោក មុំ វរេះរើង បានបង់រួចហើយនៅតុលាការកំពូលចំនួន ១៨០០០ រៀល គឺៈ-

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវដកចំនួន ៨០០ រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រឆាំងដីកាការពារចំនួន ១៤០០០ រៀល សរុប ១៨០០០ រៀល

បង្គាប់ឱ្យលោក មុំ វរេះរើង បង់ពន្ធសមាមាត្រ រួមការចំណាយការកំណត់របស់តុលាការខេត្តបាត់ដំបង ។

៤ - សាលដីកានេះប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៥៨ ។